# ព្រះរាជក្រម

នស/រកម/១២០៩/០២៦

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *



Collection by VCAT Professional Consultant

- - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - -

- - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - -

- - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - -

# ជំពូកទី ៥

# បទប្បញ្ញត្តិស្តីពីពន្ធ និង អាករ

## ផ្នែកទី ១

## ការលើកទឹកចិត្ត

## ក្នុងមណ្ឌលអភិវឌ្ឍហិរញ្ញវត្ថុ និង ក្នុងវិស័យមូលបត្រ

**មាត្រា ១១.-**

ក្នុងគោលបំណងអភិវឌ្ឍវិស័យហិរញ្ញវត្ថុប្រកបដោយចីរភាពនៅព្រះរាជាណាចក្រកម្ពុជា ត្រូវបានអនុញ្ញាតឱ្យបង្កើតមណ្ឌលអភិវឌ្ឍហិរញ្ញវត្ថុ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍហិរញ្ញវត្ថុ ។



Collection by VCAT Professional Consultant

គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍហិរញ្ញវត្ថុនេះ ស្ថិតនៅក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ទីតាំងនៃមណ្ឌលអភិវឌ្ឍហិរញ្ញវត្ថុ ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍហិរញ្ញវត្ថុ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ត្រូវបានផ្តល់ការលើកទឹកចិត្តជូនចំពោះសកម្មភាពអាជីវកម្ម នៅក្នុងមណ្ឌលអភិវឌ្ឍហិរញ្ញវត្ថុ ដែលរួមមានការលើកលែងមួយផ្នែក ឬ ទាំងស្រុងនៃពន្ធគយ និង/ឬ ពន្ធអាករ ។ ការលើកលែងពន្ធអាករផ្សេងៗនៅក្រោមការលើកទឹកចិត្តនេះ ត្រូវកំណត់មិនឱ្យលើសពីរយៈពេល ៩ ( ប្រាំបួន ) ឆ្នាំ ។ ប្រភេទសកម្មភាពអាជីវកម្មដែលត្រូវទទួលបានការលើកទឹកចិត្ត និង លក្ខខណ្ឌនៃការលើកទឹកចិត្តនេះ ត្រូវកំណត់លម្អិតដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ១២.—**

សម្រាប់អភិវឌ្ឍវិស័យមូលបត្រប្រកបដោយចីរភាព នៅព្រះរាជាណាចក្រកម្ពុជា ការលើកទឹកចិត្តនឹងត្រូវបានផ្តល់ជូនដល់សកម្មភាពពាក់ព័ន្ធនឹងវិស័យមូលបត្រ ។ ការលើកទឹកចិត្តនេះរួមមាន ការលើកលែងមួយផ្នែក ឬ ទាំងស្រុងនៃពន្ធអាករ ដែលត្រូវកំណត់មិនឱ្យលើសពីរយៈពេល ៩ ( ប្រាំបួន ) ឆ្នាំ ។

ប្រភេទសកម្មភាពដែលត្រូវទទួលបានការលើកទឹកចិត្ត និង លក្ខខណ្ឌ នៃការលើកទឹកចិត្តនេះ ត្រូវកំណត់លម្អិតដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ផ្នែកទី ២

## ពន្ធលើអចលនទ្រព្យ

**មាត្រា ១៣.—**

ផ្អែកតាមមាត្រា ៧៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ និង ក្នុងគោលបំណងវិចារណការូបនីយកម្មក្នុងការប្រើប្រាស់ដី និង ដើម្បីជា

Collection by VCAT Professional Consultant

ប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបង្កើតពន្ធលើអចលនទ្រព្យស្ថិតនៅក្នុងភូមិសាស្ត្ររដ្ឋបាលរាជធានី និង ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា ។ ពន្ធដែលត្រូវប្រមូលពីអចលនទ្រព្យនេះ តម្រូវតែលើអចលនទ្រព្យដែលមានតម្លៃលើសពី ១០០.០០០.០០០ ( មួយរយលាន ) រៀល ។

សម្រាប់គោលដៅនៃពន្ធនេះ ពាក្យ " អចលនទ្រព្យ " សំដៅដល់ ដី ផ្ទះ អគារ និង សំណង់ផ្សេងៗ ដែលសង់ភ្ជាប់នឹងដីនោះ ។

ពន្ធនេះត្រូវប្រមូលប្រចាំឆ្នាំតាមអត្រា ០,១% ( សូន្យក្បៀសមួយភាគរយ ) លើតម្លៃអចលនទ្រព្យ ។ មូលដ្ឋានគិតពន្ធគឺជាតម្លៃ ដី ផ្ទះ អគារ និង សំណង់ផ្សេងៗ ដែលសង់ភ្ជាប់នឹងដីនោះ ដោយកាត់បន្ថយនូវទឹកប្រាក់ចំនួន ១០០.០០០.០០០ ( មួយរយលាន ) រៀល ។ តម្លៃ ដី ផ្ទះ អគារ និង សំណង់ផ្សេងៗ ដែលសង់ភ្ជាប់នឹងដីនោះ ត្រូវកំណត់តាមតម្លៃទីផ្សារ ដោយគណៈកម្មការវាយតម្លៃអចលនទ្រព្យ ដែលបង្កើតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ១៤.–**

ពន្ធនេះត្រូវបានលើកលែងចំពោះអចលនទ្រព្យ ដូចខាងក្រោម ៖

ក- អចលនទ្រព្យដែលជាដីធ្លីកសិកម្ម ។

ខ- អចលនទ្រព្យដែលជាកម្មសិទ្ធិរបស់រាជរដ្ឋាភិបាល ឬ ស្ថាប័នរាជរដ្ឋាភិបាល ។

គ- អចលនទ្រព្យដែលជាកម្មសិទ្ធិរបស់សហគមន៍ ឬ បុគ្គលណាមួយដែល ៖

- ត្រូវបានរៀបចំឡើង និង ដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា និង សប្បុរសធម៌

- គ្មានចំណែកណាមួយនៃអចលនទ្រព្យ ឬ ប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាប្រយោជន៍ឯកជន

ឃ- អចលនទ្រព្យជាកម្មសិទ្ធិរបស់បេសកកម្មការទូត ឬ កុងស៊ុលបរទេស អង្គការអន្តរជាតិ និង ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ។


Collection by VCAT Professional Consultant

**មាត្រា ១៥.–**

កម្មសិទ្ធិករនៃអចលនទ្រព្យ ឬ អ្នកកាន់កាប់នៃអចលនទ្រព្យ ឬ អ្នកទទួលប្រយោជន៍ចុងក្រោយនៃអចលនទ្រព្យ ត្រូវប្រកាស និង បង់ពន្ធលើអចលនទ្រព្យនេះ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ៣០ ខែ កញ្ញា នៃឆ្នាំនីមួយៗ ជូនរដ្ឋបាលសារពើពន្ធដែលអចលនទ្រព្យនោះស្ថិតនៅ ។

**មាត្រា ១៦.–**

បទប្បញ្ញត្តិស្តីពីវិធាន និង នីតិវិធីសារពើពន្ធ ដែលបានចែងក្នុងជំពូកទី ៥ នៃច្បាប់ស្តីពីសារពើពន្ធ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ និង ច្បាប់វិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣៣០/០១០ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ និង បទប្បញ្ញត្តិស្តីពីពន្ធដារដែលពាក់ព័ន្ធ ត្រូវយកមកអនុវត្តចំពោះពន្ធលើអចលនទ្រព្យនេះ លើកលែងតែមានការកំណត់ផ្សេង ដែលមានចែងក្នុងបទប្បញ្ញត្តិនៃជំពូកនេះ ។

**មាត្រា ១៧.–**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចេញប្រកាសដើម្បីអនុវត្តការប្រមូលពន្ធលើអចលនទ្រព្យនេះ ។

## ផ្នែកទី ៣

## ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ

**មាត្រា ១៨.–**

ចំនួនប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ដែលបានកំណត់ក្នុងមាត្រា ៧ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៤/០០២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីរបៀបនៃការកំណត់ចំពោះមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ចំពោះមធ្យោបាយ



Collection by VCAT Professional Consultant

ទេសចរណ៍ ដែលមានកម្លាំងលើសពី ១២ សេះ ឡើងទៅ ត្រូវកំណត់ជាថ្មី ដូចខាងក្រោម :

| កម្លាំងសេះរបស់រថយន្តទេសចរណ៍គ្រប់ប្រភេទ | គិតពីឆ្នាំផលិត | |
|---|---|---|
| | ដល់៥ឆ្នាំ | លើសពី៥ឆ្នាំ |
| - កម្លាំងសេះលើសពី ១២សេះ ដល់ ១៧សេះ | ៥០០.០០០៛ | ៣៦០.០០០៛ |
| - កម្លាំងសេះលើសពី ១៧សេះ ដល់ ២៤សេះ | ១.៦០០.០០០៛ | ១.២០០.០០០៛ |
| - កម្លាំងលើសពី ២៤សេះ ឡើងទៅ | ២.០០០.០០០៛ | |

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ១៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២០.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

[illegible]

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

លេខ ១០៨៨ ច.ល
ដើម្បីចម្លងចែក



Collection by VCAT Professional Consultant